# ការបង្ការអំពើប្រល័យពូជសាសន៍ ៖ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## បទពិសោធន៍អប់រំប្រវត្តិសាស្ត្រនិងការអភិវឌ្ឍន៍ជាតិ

សំបូរ មាណ្ណារ៉ា

ប្រទេសកម្ពុជាមានសក្តានុពលសេដ្ឋកិច្ច និងធម្មជាតិបម្រុះគួរជាទីមោទនៈ បើយើងពិនិត្យមើលលើវិស័យសេដ្ឋកិច្ចជាសំខាន់នោះ ។ ប៉ុន្តែបើយើងនាំការរំពឹងមើលពីជ្រុងនៃសកម្មភាពមនុស្សខ្មែរក្នុងកាលប្រវត្តិវិញ យើងនឹងអាចមានការចោទជាចម្ងល់ថាតើហេតុអ្វីបានជាមានការស្លាប់មនុស្សខ្មែរដោយការអត់ឃ្លាន និងការកាប់សម្លាប់គ្នាឯងក្នុងទសវត្សរ៍៧០នោះ?

សៀវភៅប្រវត្តិសាស្ត្រ ស្តីអំពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលឆ្លុះបញ្ចាំងពីរបបមួយដែលគ្រប់គ្រងដោយពួកខ្មែរក្រហម បាន និងកំពុងទាក់ទាញមនុស្សខ្មែរចាស់ក្មេងជាច្រើនឲ្យអាន ដើម្បីស្វែងយល់តាមតែគោលគំនិតចង់បានរបស់គេរៀងៗខ្លួន ។ សកម្មភាពនេះក៏ជាការបង្កលក្ខណៈងាយស្រួលមួយក្នុងការអប់រំប្រវត្តិសាស្ត្រ សម័យកម្ពុជាប្រជាធិបតេយ្យជាសាធារណៈ ។ ប៉ុន្តែក្នុងបរិបទអប់រំវិទ្យាសាស្ត្រប្រវត្តិវិទ្យាគួរត្រូវមានគ្រឹះដែលជាផ្នែកភ្ជាប់ចំណេះដឹងប្រវត្តិសាស្ត្រដែលត្រូវឈរលើតួនាទីសង្គម និងតម្រូវការសង្គមជាការចាំបាច់ ។

ក្រោយថ្ងៃ ៧ មករា ឆ្នាំ១៩៧៩ប្រជាជាតិខ្មែរទាំងមូលបានពាំនាំនូវវិបត្តិសង្គមដ៏សែនជូរចត់ផ្សាយជូនពិភពលោក ដោយការគាំពារនូវសេចក្តីឈឺចាប់ដែលបានជួបប្រទះក្នុងសម័យខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា "កម្ពុជាប្រជាធិបតេយ្យ" ដែលផ្តើមក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ នេះគឺជាការបញ្ឈាក់រួចជាស្រេចថា យើងខ្មែរមិនចង់ឃើញខ្មែរជំនាន់ក្រោយៗ ត្រូវទទួលរងទុក្ខវេទនាបែបនេះទៀតទេ ។ ដូច្នេះដើម្បីរាំងរាមិនឲ្យមានការត្រឡប់មកវិញនូវរាល់អំពើអយុត្តិធម៌សង្គមប្រល័យជាតិឯងនេះ ការអប់រំប្រវត្តិសាស្ត្រជាតិស្តីពីសម័យកម្ពុជាប្រជាធិបតេយ្យត្រូវតែផ្អែកលើ គោលការណ៍ចម្បង ៣សំខាន់គឺ ៖

- គោលការណ៍បង្រួបបង្រួមជាតិ

- គោលការណ៍ស្នេហាជាតិ
- គោលការណ៍អភិវឌ្ឍន៍ជាតិ

## ក. គោលការណ៍បង្រួបបង្រួមជាតិ

ក្នុងបរិបទដែលប្រទេសកម្ពុជា កំពុងទទួលអំណោយផលនៃការស្តារប្រទេសឲ្យមានវឌ្ឍនភាពក្រោមការជួយជ្រោមជ្រែងពីអន្តរជាតិ និងប្រជាជាតិផ្ទាល់ខ្លួននោះ ការនាំប្រទេសឲ្យមានសន្តិភាពគឺជាកត្តាគន្លឹះបំផុត ។ អ្នកអប់រំប្រវត្តិសាស្ត្រជាតិអំពីសម័យកម្ពុជាប្រជាធិតេយ្យ គួរគប្បីទាញយកតែគោលព្រឹត្តិការណ៍សំខាន់ៗណាដែលអាចធ្វើឲ្យសិស្សយល់បានថា ការឈឺចាប់ទាំងឡាយនោះបន្តដោយពួកក្រុមមេដឹកនាំកំពូលៗ ដោយមិនផ្តោតសកម្មភាពកំហុសសំដៅលើក្រុមកម្មាភិបាលតូចតាចដែលអាចជាឆ្នួនបំភិតបំភ័យនាំភាពអសកម្មដែលផ្ទុយទៅនឹងបរិបទសន្តិភាពរបស់សង្គមនាពេលបច្ចុប្បន្ន ។ ប្រការដែលត្រូវប្រកាន់គោលការណ៍នេះជាបឋមគឺមានន័យថា អ្នកអប់រំត្រូវប្រកាន់គោលជំហរបង្រួបបង្រួមជាតិដោយការយកវិធីអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជា ប្រជាធិបតេយ្យជាកញ្ចក់ឆ្លុះអំពីភាពគ្មានលំនឹងនយោបាយ ភាពមិនទុកចិត្តគ្នា ការគុំគួនប្រវត្តិសាស្ត្រ និងការគ្មានយុត្តិធម៌សង្គម ថាដើមហេតុនៃការបែកបាក់សង្គមជាតិ ។ យោងលើកិច្ចការអប់រំដែលអាចទាញបញ្ជាក់ពីព្រឹត្តិការណ៍នៃសម័យកម្ពុជាប្រជាធិបតេយ្យ ដោយព្យាយាមបញ្ចូលគោលគំនិតអប់រំឲ្យមានសមានចិត្តស្រឡាញ់គ្នា គោរពសិទ្ធិ និងយោគយល់គ្នា អ្នកអប់រំអាចសម្រេចគោលការណ៍បង្រួបបង្រួមជាតិបាន ។ ទោះជាយ៉ាងនេះក្តី ការអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវតែរួមបញ្ចូលគោលការណ៍អប់រំជាតិនិយមដែរ ។

## ខ. គោលការណ៍ស្នេហាជាតិ

ស្មារតីបង្រួបបង្រួមជាតិជាមធ្យោបាយសម្រាប់ឈានដល់ការសម្រេចគោលការណ៍ស្នេហាជាតិដែលជាតួនាទីមួយទៀតក្នុងការអប់រំប្រវត្តិសាស្ត្រ ។ អ្នកអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវតែមានគោលចំណុចសកម្មសម្រាប់អប់រំអំពីភក្តីភាព ចំពោះជាតិដោយគូសបង្ហាញពីការបាត់បង់នូវមនសិកាជាតិនិយមរបស់មេដឹកនាំសម័យកម្ពុជាប្រជាធិបតេយ្យមកធ្វើការបញ្ជាក់ ។ ដើម្បីផ្តោតចំណាប់អារម្មណ៍លើកិច្ចការនេះ ការចាប់យកព្រឹត្តិការណ៍អាជ្ញានិយមអត្តទត្តនិយម និងផ្តាច់ការនិយម ដែលជាទង្វើរបស់មេដឹកនាំសម័យកម្ពុជាប្រជាធិបតេយ្យមកធ្វើជាភស្តុតាង អាចនាំមកនូវការវិនិច្ឆ័យពីកត្តាក្បត់ជាតិឯងរបស់មេដឹកនាំទាំងនោះ ។ ដូច្នេះគោលការណ៍អប់រំប្រវត្តិសាស្ត្រជាតិអំពីសម័យកម្ពុជាប្រជាធិបតេយ្យ អាចទាញបង្ហាញបានយ៉ាងងាយថា ការគ្មានមនសិការស្នេហាជាតិគឺជាការមោទនៈជ្រុលនិយម រហូតដល់មានការប្រកួតប្រជែងដោយមិនបានគិតពីផលវិបាករបស់ជាតិនា

ពេលអនាគត ។ ដោយឈរលើមូលដ្ឋានគំនិតស្នេហាជាតិ អ្នកអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យ អាចបណ្តុះបាននូវទឹកចិត្តលះបង់ទាំងឡាយដើម្បីជាតិ សម្រាប់ជាជំហរដ៏មុតមាំក្នុងគោលការណ៍អភិវឌ្ឍន៍ដែលជាតម្រូវការចាំបាច់របស់សង្គមកំពុងអភិវឌ្ឍន៍នៃកម្ពុជាបច្ចុប្បន្ន ។

## គ. គោលការណ៍អភិវឌ្ឍន៍ជាតិ

សកម្មភាពសង្គមមួយមានដំណើរការអភិវឌ្ឍន៍បាន លុះណាតែមានសមាជិកសង្គមមានថាមពលគ្រប់គ្រាន់ទាំងស្មារតី បញ្ញាញាណ និងពលកម្ម ។ អ្នកអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យត្រូវតែប្រកាន់គោលការណ៍អភិវឌ្ឍន៍ជាតិ ដោយផ្តោតការប្រៀបធៀបគំនិតអប់រំ ក្នុងសម័យនេះជាមួយសម័យជឿនលឿនណាមួយ ។ លើសពីនេះ អ្នកអប់រំគួរសកម្មទាញយកព្រឹត្តិការណ៍ណាដែលអាចបង្ហាញថា ជាគោលនយោបាយបញ្ច្រាសទិសអភិវឌ្ឍន៍នៃសម័យកម្ពុជាប្រជាធិបតេយ្យមកធ្វើជាភស្តុតាងបញ្ជាក់ ។ ប៉ុន្តែ អ្នកអប់រំប្រវត្តិសាស្ត្រជាតិចាំបាច់ណាស់ត្រូវយល់ថា មាគ៌ាអភិវឌ្ឍន៍ត្រូវប្រកបដោយសកម្មភាពអ្វីជាមូលដ្ឋាន ដើម្បីធ្វើជាទុនត្រិះរិះពិចារណារកបទពិសោធន៍ប្រវត្តិសាស្ត្រមកធ្វើជាបទពិពណ៌នាបង្ហាញ ។

សម័យកម្ពុជាប្រជាធិបតេយ្យ ពោរពេញទៅដោយព្រឹត្តិការណ៍ជាប្រវត្តិដែលអាចយកមកបញ្ជាក់បានអំពីការដើរបញ្ច្រាសទិសរបស់អង្គការបដិវត្តថ្នាក់កំពូល ដោយបានបង្ខំប្រជាជនខ្មែរឲ្យទទួលយកភាពផ្តាច់ការបដិវត្ត ដែលជាមូលហេតុនៃការបំផ្លាញកម្លាំងពលកម្មសង្គមដ៏ខ្លាំងក្លា ។ ជាមួយនេះនេះដែរការបំបាត់សិទ្ធិសេរីភាពក្នុងការទទួលពុទ្ធិដើម្បីកិច្ចអភិវឌ្ឍន៍ ក៏ជាកត្តាដែលត្រូវលើកមកធ្វើការអប់រំប្រវត្តិសាស្ត្រ អំពីសម័យកម្ពុជាប្រជាធិបតេយ្យដែរ ។ បំបាត់សមត្ថភាពជំនាញ បង្ខំការងារដោយមិនរវល់ពីការផ្តល់ឱកាសដែលជាការកំណត់ឯកត្តភាពការងារគឺជាការកាត់បន្ថយភាពជឿនលឿនដែលមិនបានជ្រើសរើសជំនាញសកម្មសម្រាប់ការងារដែលអារ្យសង្គមក្នុងលោកបានអនុវត្ត ។ ដូច្នេះការកំចាត់ធនធានមនុស្សសកម្ម លើវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលអ្នកដឹកនាំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តិចំពោះមនុស្សខ្មែរគឺជាមេរៀនប្រវត្តិសាស្ត្រសម្រាប់ជនជំនាន់ក្រោយត្រូវប្រុងប្រយត្ន័ជៀសឲ្យបាន ។

ទាំងនេះជាគោលវិធីនៃការអប់រំប្រវត្តិសាស្ត្រជាតិអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃបរិបទកម្ពុជានាសម័យទំនើបដែលកំពុងឆក់ឱកាសសម្រាប់ស្ថាបនាជាតិ ក្រោយពីការដួលរលំរបបអតីតកាលមួយនេះ ។ តែទោះជាមានការពិចារណាលើមូលបទកិច្ចការអប់រំប្រវត្តិសាស្ត្រជាតិ ដោយឈរលើគោលការណ៍ជាមូលដ្ឋានទាំងបីខាងលើនេះក៏ដោយ យើងនៅតែមានភាពទូលាយជានិច្ចក្នុងការប្រើគោលវិធីដទៃណាដែលត្រូវបានវិភាគល្អិតល្អន់ថាជាការចាំបាច់ត្រូវតែអនុវត្ត ។

ជាបន្ថែមទៀត ដើម្បីគោរពគោលការណ៍អប់រំដែលត្រូវតែមានភាពឥតខ្ចោះ នោះការបើកទូលាយគួរតែត្រូវធ្វើឡើងដោយយោងទៅតាមលក្ខ័ណ្ឌជាក់ស្តែងនៃមជ្ឈដ្ឋានអប់រំ និងកម្រិតអប់រំ មូលដ្ឋាន ។

ក្នុងលទ្ធភាពបង្ហាញដោយការប្រើគោលចំណុចសំខាន់ៗទាំងឡាយនៃប្រវត្តិព្រឹត្តិការណ៍ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែលគួរគប្បីធ្វើការពិចារណាផ្នែកខាងក្រោមនេះ គឺជាកម្រងចំណុចព្រឹត្តិការណ៍ទាំងនោះ ។

## សម្រាប់គោលការណ៍បង្រួបបង្រួមជាតិ

-ការជម្លៀសប្រជាជនចេញពីទីក្រុង និងការកំណត់លក្ខណៈប្រជាជនតាមរយៈកាលធ្វើបដិវត្ត និងទីតាំង (ទំព័រ ១៨-២១) ។

-ការកំណត់ប្រភេទប្រជាជនដើម្បីកាន់អំណាច និងភាពលម្អៀងរបស់អង្គការ (ទំព័រ២១)

-ការសង្ស័យគ្នាដោយបំពាក់ការតាមដានគ្នាជាគោលជំហរអ្នកបដិវត្ត (ទំព័រ៣៨-៥៥)

-ការបង្កភាពរើសអើងក្នុងសង្គមបដិវត្ត អ្នកមូលដ្ឋាន និងអ្នកថ្មី (ទំព័រ៤៧-៣៨)

-បំបាត់សម្ពន្ធ័ភាពសង្គម និងគ្រួសារ (ទំព័រ៣២)

-បំបែកតួនាទីបុរស និងស្ត្រីក្នុងកិច្ចការសង្គមគ្រួសារ (ទំព័រ៣២)

-ការអប់រំកុមារផ្តាច់ទំនាក់ទំនងជាមួយឪពុកម្តាយ (ទំព័រ៣២-៤៥)

-បក្សសម្ពន្ធ័បដិវត្ត (ទំព័រ ២៧)

## សម្រាប់គោលការណ៍ស្នេហាជាតិ

-ការប្រណាំងប្រជែងគ្នាក្នុងបក្ស (ទំព័រ២៧)

-គិតការងារបក្សជាងការងារជាតិ (ទំព័រ២៧)

-ការប្រើប្រាស់ប្រជាជនជាឧបករណ៍បំបែកបក្ស (ទំព័រ ៤៧-៤៨)

-ការមិនស្វែងយល់ពីផលវិបាកជាតិដោយលុះតាមមនោគមន៍វិជ្ជាបរទេស (ទំព័រ៣៣)

## សម្រាប់គោលការណ៍អភិវឌ្ឍន៍ជាតិ

-ការចល័តមនុស្ស (ទំព័រ២០-២១)

-ភាពគ្មានសាលារៀន និងការបណ្តុះបណ្តាល (ទំព័រ៣៣-៤២)

-ការបោទប្រកាន់មនុស្សធ្វើទារុណកម្ម និងបង្អត់អាហារ (ទំព័រ៣៣-៤៦-៤៧)

-ភាពគ្មានលក្ខណៈវិទ្យាសាស្ត្រក្នុងវិស័យសេដ្ឋកិច្ច (ទំព័រ ៣៣)

-ការបិទទ្វារ មិនមានទំនាក់ទំនងអន្តរជាតិទូលាយ (ទំព័រ២១)

-កំណត់ការងារកសិកម្មជាអាទិភាពដោយគ្មានជម្រើសការងារ (ទំព័រ៣២)

-បំបាត់សិទ្ធិសម្រេច សិទ្ធិស្វែងយល់ ការពិភាក្សា និងការតវ៉ា (ទំព័រ ៥៥)

## សេចក្ដីសន្និដ្ឋាន

យោងតាមការរៀបរាប់ទាំងអស់ខាងលើ យើងសង្ឃឹមថាការអប់រំប្រវត្តិសាស្ត្រជាតិអំពីសម័យកម្ពុជាប្រជាធិបតេយ្យ នឹងទទួលផ្លែផ្កាដ៏ប្រសើរដោយបណ្ដុះអ្នកសន្តិភាពនិយម អ្នកជាតិនិយម និងជនចម្រើន សម្រាប់ចូលរួមយ៉ាងសកម្មក្នុងកិច្ចការស្ថាបនារបស់កម្ពុជាដែលជាភារកិច្ចចាំបំផុតនាពេលបច្ចុប្បន្ន ។ ជាមួយនេះដែរ ការបង្ហាញជនជំនាន់ក្រោយអំពីអំពើអយុត្តិធម៌សង្គមនៃសម័យកម្ពុជាប្រជាធិបតេយ្យ គឺមិនមែនជាការបំបែកបំបាក់ជាតិ តែគឺជាការបំពាក់ស្មារតីរួបរួមជាតិដោយនាំឲ្យគេបានយល់និងកំណត់ខ្លួនដើម្បីបញ្ចៀសរាល់ដានអសកម្មមិនរីកចម្រើនទាំងឡាយ ដែលបង្កើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ម្យ៉ាងទៀត ការបង្ហាញបទពិសោធន៍ប្រវត្តិសាស្ត្រដែលប្រជាជនខ្មែរឆ្លងកាត់នៅសម័យនោះនឹងនាំចិត្តជនជំនាន់ក្រោយឲ្យចេះពិចារណា អំពីការចេះស្រឡាញ់គោរពមនុស្សចាស់របស់គេដែលនៅមានជីវិតនៅឡើយ ហើយនេះគឺជាការអប់រំសង្គមយ៉ាងប្រសើរក្នុងន័យសីលធម៌ ។ ជាមួយនេះដែរការយកព្រឹត្តិការណ៍ប្រវត្តិនៃសម័យដ៏ជូរចត់នេះធ្វើជាមេរៀនប្រវត្តិសាស្ត្រ ដើម្បីធ្វើការវិនិច្ឆ័យនៃជនជំនាន់ក្រោយគឺជាវិទ្យាសាស្ត្រអប់រំហើយមិនមែនសម្រាប់តែជនកម្ពុជាតែប៉ុណ្ណោះទេ តែក៏សម្រាប់ការអប់រំមនុស្សនៃពិភពលោកដែរ ។

ជាអវសានមតិយើងខ្ញុំសូមឲ្យមានការចូលរួមយ៉ាងសកម្មក្នុងកិច្ចការអប់រំប្រវត្តិសាស្ត្រជាតិដោយខិតខំគោរពតាមគោលការណ៍ទាំងបីខាងលើជាប្រចាំដើម្បីបង្កើតបាននូវសុខសន្តិភាពសម្រាប់ជាតិ តំបន់ និងពិភពលោកទាំងមូល ។ សូមឲ្យការសិក្សាប្រវត្តិសាស្ត្រដើម្បីសន្តិភាព ។